ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល   ជាតិ   សាសនា   ព្រះមហាក្សត្រ

សភាជំនុំរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី   តាំងនាមប្រជារាស្ត្រខ្មែរ

លេខ ៨៧

ចុះថ្ងៃទី២៣ខែមិនាឆ្នាំ១៩៩៨   តុលាការកំពូល

សាលដីកា

លេខ ០៧

ចុះថ្ងៃទី១២ខែមករាឆ្នាំ១៩៩៩

បានបើកសវនាការ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩ ដោយមានសមាសភាព ដូចខាងក្រោម :

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន

២ - លោក ម៉ែន ស៊ីន ចៅក្រម

៣ -- លោក ទេវ៉ុល មួន ចៅក្រម

៤ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥ - លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី

លោក ទេព្យ ឌុង

តំណាងមហាអយ្យការ

លោក ហាង ហាវី ជាព្រះរាជអាជ្ញា

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៦៦៥ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ និង សំណុំរឿងរដ្ឋប្បវេណីលេខ ៧១៣ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៧ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ណន ម៉ៅ ភេទប្រុស អាយុ៥៥ឆ្នាំ សញ្ជាតិកម្ពុជា របរកសិករធ្វើស្រែចំការ ទីលំនៅ ភូមិទួលស្វាយ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ នៅ ណន " ស " ម្តាយឈ្មោះ ភ្លូ ថា " រ " ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ នៅ ម៉ាក ភេទស្រី អាយុ៥៥ឆ្នាំ សញ្ជាតិកម្ពុជា របរកសិ ធ្វើស្រែ ទីលំនៅ ភូមិទួលស្វាយ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្ត កណ្តាល ឪពុកឈ្មោះ ទៀន នៅ " ស " ម្តាយឈ្មោះ អ៊ុំ ទៀន " ស " ។

និង ឈ្មោះ នៅ ម៉ាន ភេទស្រី អាយុ៦៧ឆ្នាំ សញ្ជាតិកម្ពុជា របរកសិ ធ្វើស្រែ ទីលំនៅ ភូមិទួលស្វាយ ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ ទៀន នៅ " ស " ម្តាយឈ្មោះ អ៊ុំ ទៀន " ស " ។

ក ម្ម វ ត្ថុ ប ណ្តឹ ង : ប្តឹងសុំសិទ្ធិកាន់កាប់ដី ។

តាមពាក្យបណ្តឹងសាទុក្ខលេខ ២៧១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៧ របស់លោក ណន ម៉ៅ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេច ទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៨៧ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៨៨ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៨-១១-៨៦ របស់ដើមចោទឈ្មោះ ឈន ម៉ៅ បញ្ជាក់ថា ក្រោយពីខ្លួនរៀបការហើយ ឪពុករបស់ខ្លួនឈ្មោះ អ៊ុំ មឿន បានចែកដីអោយខ្លួនមួយកន្លែង សំរាប់សង់ផ្ទះ ក្រោយពីសង់ផ្ទះបាន ៣ ឆ្នាំ កស្រាប់តែមីងរបស់ខ្លួនត្រូវជាកូនរបស់ អ៊ុំ មឿន ឈ្មោះ នៅ ម៉ាន និង នៅ ម៉ាក់ មកទាមទារដី និង អោយខ្លួនរុះផ្ទះចេញ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១០ "ក" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៨៧ របស់ តុលាការ ខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៨-១១-៨៦ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២ - ប្រគល់អោយសិទ្ធិឈ្មោះ ឈន ម៉ៅ "ដើមចោទ" កាន់កាប់ដីបន្តពីឈ្មោះ អ៊ុំ មឿន ដែលមានទំហំ និង ព្រំប្រទល់ តាមបណ្ណសំគាល់សិទ្ធិលេខ ឥ.០៣៤០ ចុះថ្ងៃទី ១០-១២-៨៤ ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៣ - បង្គាប់អោយ នៅ ម៉ាន, នៅ ម៉ាក "ចុងចម្លើយ" បង់ប្រាក់ប្រដាប់ក្តី ចំនួន ៧.០០០៛០០ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ១.៨០០៛០០
- រង្វាន់ក្រឡាបញ្ជីការទិបប្រាក់ចំនួន ២០០៛០០
- ប្រាក់សំណងក្នុងកិច្ចស៊ើបសួរ ចំនួន ៥.០០០៛០០

ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់រួចហើយតែអោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

- កាលបើប្តឹងឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយឈ្មោះ នៅ ម៉ាន, នៅ ម៉ាក បង់ពន្ធលខាមាត្រ មួយភាគរយ លើតំលៃដីស្មើ ១០.០០០៛០០ "មួយម៉ឺន" ប្រាក់នេះត្រូវបង់ចូលថវិកាជាតិ ៨០ភាគរយ ស្មើ ៨.០០០៛០០ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ចំនួន ២០ភាគរយ ស្មើ ២.០០០៛០០ ។ ប្រាក់នេះដើមចោទត្រូវបង់ជាមុនដែរ ហើយអោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

៤ - សាលក្រមនេះ ប្រកាស ជាសាធារណៈ ចំពោះមុខគូក្តី ។ គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣-៤-៨៧ របស់ឈ្មោះ នៅ ម៉ាក ប្តឹងមិនសុខចិត្តនឹង សាលក្រមរបស់ តុលាការខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៦៦៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៨៧ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេច ដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍ របស់ចុងចម្លើយឈ្មោះ នៅ ម៉ាក ចុះថ្ងៃទី ២៣-៤-៨៧ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២ - បដិសេធ សាលក្រមលេខ ១០ "ក" ចុះថ្ងៃទី ០៤-៤-១៩៨៧ របស់ តុលាការ ខេត្តកណ្តាល ចោលជាអសារបង់ ។

៣ - ប្រគល់ដីទំនាស់ដែលមានទំហំ និង ព្រំប្រទល់ តាមបណ្ណសំគាល់កម្មសិទ្ធិលេខ -

៨៤.០៣៤០ ចុះថ្ងៃទី ១០-២-១៩៩២ អោយទៅចុងចម្លើយឈ្មោះ ទៅ ម៉ាក និង ទៅ ម៉ាន កាន់កាប់ទុកជាមរតក ចាប់តាំងពី សាលដីកានេះចូលជាស្ថាពរ ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីដែល សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛០០ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី និង ពន្ធតឹង ២.៥៥០៛០០ ទង្វាន់ក្រមឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛០០ ចំណាយក្នុងកិច្ចប្រជុំដីកាកោះ ៥.០០០៛០០ និង ចំណាយលើការជំនុំជំរះតុលាការ ៥.០០០៛០០ សរុប ១៣.០០០៛០០ ។

កាលបើបណ្តឹងសាទុក្ខ បង្គាប់អោយដើមចោទឈ្មោះ ឈន ម៉ៅ សងប្រាក់ប្រដាប់ក្តី ចំនួន ១៣.០០០៛០០ អោយទៅចុងចម្លើយវិញ និង បង្គាប់អោយបង់ពន្ធសមាមាត្រ ខ្មួរភាគរយ នៃតម្លៃដីទំនាស់ ។

៥ - សាលដីកានេះ ជំនុំជំរះ និង ប្រកាស ជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ៤៣១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៧ របស់ឈ្មោះ ឈន ម៉ៅ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សារណាចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះ ឈន ម៉ៅ

បានឃើញ សារណាឆ្លើយតប របស់ឈ្មោះ ទៅ ម៉ាន និង ទៅ ម៉ាក ចុះថ្ងៃទី ១២ - ខែតុលា ឆ្នាំ១៩៩៨

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

សាលដីការបស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និង គតិច្បាប់ហើយ ស្នើក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់តទៅ ។

ឈ្មោះ ឈន ម៉ៅ បានឆ្លើយថា : ដីនេះប្រធានភូមិ បានចែកអោយខ្លួននៅ ហើយខ្លួនក៏បានធ្វើផ្ទះលើដីនោះនៅរហូតមក តែក្រោយមកនៅពេលដែលមានរឿងទាស់ទែងមក ទៅ ម៉ាន និង ទៅ ម៉ាក គាត់បានដេញខ្លួនចេញពីដីនេះ ឯគាត់មានដីសំរាប់រស់នៅទៀងពួនខ្លួន ចំណែកដីរបស់ខ្លួនមានផ្ទះតំណាងម្ចាស់ស្ថានទទួលស្គាល់ត្រឹមត្រូវតាមច្បាប់គ្រប់គ្រាន់ទាំងអស់ ។

ឈ្មោះ ទៅ ម៉ាន បានឆ្លើយថា : ឈន ម៉ៅ នេះជាចៅរបស់ អ៊ុំ ខៀន ពិតមែន តែវាបានមកចែកយកភាគត្រូវរបស់ខ្លួន គឺគេបានធ្វើបង់ខ្លួនមិនបានមកជួយថែរក្សាខ្លួននៅពេលដែលខ្លួនមានជំងឺ ដូច្នេះខ្លួនសុំដកយកដីនេះមកវិញទុកអោយកូនវិញ ។

ឈ្មោះ ទៅ ម៉ាក បានឆ្លើយថា : ឈន ម៉ៅ នេះបានកាប់បំផ្លាញស្លាបវាររបស់ខ្លួនខ្លាំងណាស់ ខ្លួនបានសុំដីនេះពីប្រធានភូមិសំរាប់ទុកអោយគេ តែប្រធានភូមិគាត់ថាចែកអោយប្រជារាស្ត្រក្នុងភូមិដូចគ្នា ដល់ពេលគាត់ចែកអស់ហើយទើបប្រធានភូមិចែកទុកអោយគេ ហើយឈ្មោះនេះបានចាកចេញពីលំនៅដ្ឋានបាត់យូរណាស់មកហើយ ឈន ម៉ៅ នេះបានចោទថាខ្លួនលួចផ្លង់របស់គេ នេះគឺជាពាក្យមិនពិតទេ សូមលោកប្រធាន មេត្តាជួយពិចារណា ។

ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី .

ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៧២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៨៧ របស់ លោក ណន ម៉ៅ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើកយករឿងនេះមក ជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ សាលាជំរះក្តី ។

- យល់ឃើញថា ការដែល សាលាឧទ្ធរណ៍ សំរេចប្រគល់ដីទាំងអស់ទៅ អោយ ចុងចម្លើយ អ្នកស្រី នៅ ម៉ាន និង អ្នកស្រី នៅ ម៉ាក កាន់កាប់ទុកជាមរតក ដោយអាងហេតុថា ចុងចម្លើយទាំងពីរនាក់ជាកូនរបស់ខ្មោចលោកយាយ អ៊ុំ ម៉ឿន នោះជាការភាន់ច្រឡំ ពីព្រោះ ចាប់តាំងពីថ្ងៃ ៧មករា ១៩៧៩ មកលោក ណន ម៉ៅ ក៏ជាសមាជិកគ្រួសារលោកយាយ អ៊ុំ ម៉ឿន ដូចអ្នកស្រី នៅ ម៉ាន និង អ្នកស្រី នៅ ម៉ាក ដែរ ហើយអ្នកស្រី នៅ ម៉ាន ក្តី អ្នកស្រី នៅ ម៉ាក ក្តី ក៏បានទទួលចំណែកដី និង ផ្ទះពីលោកយាយ អ៊ុំ ម៉ឿន និង ពីរដ្ឋអំណាចមូលដ្ឋានរួចមកហើយដែរ ដូច្នេះ លោក ណន ម៉ៅ ក៏មានសិទ្ធិទទួលចំណែកដីដែលលោកយាយ អ៊ុំ ម៉ឿន បានអោយសង់ផ្ទះស្នាក់នៅតាំងពីឆ្នាំ១៩៨៣ រហូតមក ទោះក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី មានឈ្មោះលោកយាយ អ៊ុំ ម៉ឿន ជាម្ចាស់កម្មសិទ្ធិក៏ដោយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៦៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៨៧ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១ - ទទួលបណ្តឹងសាទុក្ខលេខ ៤៧២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៨៧ របស់លោក ណន ម៉ៅ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ ៦៦៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៨៧ របស់ សាលាឧទ្ធរណ៍ ទាំងមូល ។

៣ - បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៨៣ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៨៨ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បី ជំនុំជំរះ ជាថ្មីឡើងវិញ ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ណន ម៉ៅ បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប៊ិចចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការពិតប្រាក់,
- ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយត្រូវអោយអ្នកស្រី នៅ ម៉ាន និង អ្នកស្រី នៅ ម៉ាក សងប្រាក់ចំនួន ១៩.០០០រៀល នេះទៅអោយលោក ណន ម៉ៅ វិញ ។

៥ - សាលដីកានេះ ប្រកាស នាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១២ ខែមករា ឆ្នាំ១៩៨៩ ។